គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ១០ ចេញផ្សាយថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១
No. 10 Released on September 07, 2021

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# អត្ថគាហកៈ និងសិទ្ធិរបស់អត្ថគាហកៈ
## Beneficiary and Beneficiary's Rights




រូបភាព | Picture: https://www.thebalance.com/what-is-a-trust-fund-357254

នៅក្នុងច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩) ត្រង់មាត្រាទី២៦ និងទី២៧ បានចែងពីអត្ថគាហកៈ និងសិទ្ធិរបស់អត្ថគាហកៈ។ មាត្រាទាំង ២នេះមានសារៈសំខាន់ណាស់ ហើយអត្ថគាហកៈគ្រប់រូបគប្បីយល់ដឹង។ មាត្រាទី២៦បានចែងថា អត្ថគាហកៈអាចជាបុគ្គលដែលត្រូវបានបង្កើតស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ឬអាចជាបរធនបាលទាយក។ អត្ថគាហកៈអាចទទួលផលពីបរធនបាលកិច្ច ចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃបរធរបាលកិច្ច លើកលែងតែមានបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។ ករណីដែលមានអត្ថគាហកៈច្រើន អត្ថគាហកៈទាំងនេះអាចទទួលផលដូចគ្នា ឬផ្សេងៗពីគ្នាតាមរបៀបឬវិធីដែលមានចែងក្នុងលិខិតបរធនបាលកិច្ច។

ករណីដែលគ្មានរបៀប ឬវិធីទទួលផលដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវសន្មតថាអត្ថគាហកៈទាំងនេះទទួលផលស្មើៗគ្នា។

ចំណែកសិទ្ធិរបស់អត្ថគាហកៈត្រូវបានចែងក្នុងមាត្រា២៧ ថា អត្ថគាហកៈមានសិទ្ធិជាអាទិ៍ដូចជា÷ **(១)** ទទួលអត្ថប្រយោជន៍ដូចដែលមានចែងក្នុងលិខិតបរធនបាលកិច្ច, **(២)** ទាមទារឱ្យបរធនបាលបំពេញកាតព្វកិច្ចដែលបានកំណត់ក្នុងលិខិតបរធរបាលកិច្ច និងតាមបទប្បញ្ញត្តិជាធរមាន, **(៣)** ទទួលព័ត៌មានដែលពាក់ព័ន្ធនឹងការគ្រប់គ្រងនិងចាត់ចែងនៃបរធនបាលកិច្ច និង **(៤)** សិទ្ធិផ្សេងៗទៀតដែលមានចែងក្នុងលិខិតបរធនបាលកិច្ចនិងបទប្បញ្ញត្តិជាធរមាន។

Article 26 and 27 of the Law on Trust (2019) state about the beneficiary and the beneficiary's rights. These two articles are very important and should be understood by all beneficiaries. Article 26 states that the beneficiary may be a person legally established in the Kingdom of Cambodia or may be a trustor. Beneficiary may benefit from the trust from the date of entry into force of the trust, unless there are other relevant provisions. In the case of multiple beneficiaries, these beneficiaries may receive the same or different benefits in the method specified in the trust instrument.

In cases where there is no method of receiving benefits as stated in the above paragraph, it shall be assumed that these benefits are equally beneficial.

The rights of the beneficiary are stated in Article 27 that the beneficiary has the following rights: **(1)** to receive benefits as stated in the trust instrument, **(2)** to require the trustee to fulfill the obligations set out in the trust instrument and in accordance with the regulations in force, and (3) to receive information related to the management and administration of the trust and **(4)** other rights stated in the trust instrument and regulations in force.

**អត្ថបទ៖ ណង សេរីវុធ | Article: Sereyvuth Nong**

**ឯកសារយោង | References**:

- ច្បាប់ស្តីពីបរធនបាលកិច្ច. (២០១៩).

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.